**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៦......សហវ.....

# សារាចរ
# ស្តីពី
# យន្តការដោះស្រាយបញ្ហាប្រឈម ក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងឈានមកដល់ដំណាក់កាលនៃការផ្លាស់ប្តូរដ៏សំខាន់ ទាំងរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង ទាំងយន្តការនិងនីតិវិធីនៃកិច្ចដំណើរការ ជាពិសេសតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ ចាប់ពីឆ្នាំ២០១៥ តទៅ។ ការផ្លាស់ប្តូរនានានៅក្នុងដំណាក់កាលនេះ បានបង្កើតឱ្យមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមានការពិនិត្យ តាមដាន និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការកំណត់បញ្ហាប្រឈមឱ្យបានជាក់លាក់ និងចាត់វិធានការណ៍ដោះស្រាយជាបន្ទាន់ សំដៅធានាជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានវឌ្ឍនាការ ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព។

នៅក្នុងបរិការណ៍នេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) សម្រេចដាក់ចេញនូវយន្តការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចតទៅ ÷

## ក. យន្តការសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បញ្ហាប្រឈមនានា រួមទាំងភាពមិនច្បាស់លាស់ ឬអសង្គតិភាពនៃការបកស្រាយ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការអនុវត្តថវិកាកម្មវិធី នៅក្នុងក្របខណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជានៅក្រសួង ស្ថាប័ន ទាំងឡាយដែលអនុវត្តថវិកាកម្មវិធីពេញលេញ ត្រូវកំណត់ឱ្យបានជាក់លាក់ និងពិនិត្យដោះស្រាយ ជាជំហានបឋម ដោយអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ឬមានការណែនាំបញ្ជាក់បន្ថែម តាមការចាំបាច់ ដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ដែលទទួលបន្ទុកអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធនោះ។

ក្នុងករណីដែលបញ្ហាទាំងនោះ នៅតែពុំអាចដោះស្រាយបាន ក្នុងជំហានបឋម អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ត្រូវរៀបចំលិខិតស្នើសុំការពិនិត្យនិងដោះស្រាយ មកអគ្គលេខាធិការដ្ឋាន នៃ **គ.ហ.ស.** (**អ.គ.ហ.**) ដោយកំណត់និងគូសបញ្ជាក់អំពីកម្មវត្ថុនៃចំណោទបញ្ហា និងមូលហេតុ/ប្រភពនៃបញ្ហាប្រឈម ឱ្យបានច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងករណីដែលបញ្ហាប្រឈម ដែលបានលើកឡើង មានលក្ខណៈមិនទាន់ជាក់លាក់ **អ.គ.ហ.** អាចចាត់បញ្ជូនមន្ត្រីជំនាញរបស់ខ្លួន ទៅពិនិត្យ និងសិក្សាបន្ថែម តាមការចាំបាច់ នៅសាមីអគ្គនាយកដ្ឋានឬអង្គភាពជំនាញ ឬអញ្ជើញថ្នាក់ដឹកនាំ ឬមន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ ចូលរួមប្រជុំ ដើម្បីពិនិត្យនិងដោះស្រាយ។

**អ.គ.ហ.** ត្រូវពិនិត្យនិងដោះស្រាយ តាមរយៈលិខិតឆ្លើយតប ទៅកាន់អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ក្នុងរយៈពេលដ៏ឆាប់បំផុត ដោយចម្លងជូន ប្រធាន **គ.ហ.ស.** ជ្រាបជារបាយការណ៍។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ប្រសិនបើបញ្ហាប្រឈមមានការពាក់ព័ន្ធនឹងប្រព័ន្ធ យន្តការ ឬក្របខណ្ឌគតិយុត្ត នៃការងារកែទម្រង់ ដែលពុំអាចដោះស្រាយបានក្នុងកម្រិតជំនាញ អ.គ.ហ. ត្រូវស្នើសុំការពិនិត្យនិងសម្រេចជាវិធានការណ៍ដំណោះស្រាយ ពីប្រធាន គ.ហ.ស. ដោយលើកឡើងនូវសំណើជម្រើសជាក់លាក់នៃវិធានការណ៍ដំណោះស្រាយនីមួយៗ ដោយបញ្ជាក់អំពីមូលហេតុ និងផលវិបាកពាក់ព័ន្ធ។

ការសម្រេចរបស់ប្រធាន គ.ហ.ស. នឹងត្រូវរៀបចំនិងដាក់ឱ្យអនុវត្ត ក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ប្រធាន គ.ហ.ស. និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមាន អ.គ.ហ. ជាលេខាធិការ។

ការសម្រេចជាវិធានការណ៍ដំណោះស្រាយ ក្រោមទម្រង់ជាលិខិតបទដ្ឋានគតិយុត្តនានា ដោយ គ.ហ.ស. ត្រូវផ្សព្វផ្សាយ និងណែនាំអនុវត្ត ដោយទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ដោយ អ.គ.ហ. ដែលត្រូវរាយការណ៍ជូនប្រធាន គ.ហ.ស. តាមកាលកំណត់ជាធរមាន។

**ខ. យន្តការសម្រាប់ក្រសួង ស្ថាប័ន**

ក្រសួង ស្ថាប័ន ទាំងឡាយណាដែលជួបប្រទះបញ្ហាប្រឈមនានាដែលកើតចេញពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តថវិកាកម្មវិធីពេញលេញ ត្រូវរៀបចំលិខិតស្នើសុំការពិនិត្យនិងដោះស្រាយ មក អ.គ.ហ. តាមរយៈក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ក.ហ.ស.) របស់សាមីក្រសួង ស្ថាប័ន ដោយកំណត់និងគូសបញ្ជាក់អំពីកម្មវត្ថុនៃចំណោទបញ្ហា និងមូលហេតុ/ប្រភពនៃបញ្ហាប្រឈមឱ្យបានច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

អ.គ.ហ. ត្រូវពិនិត្យនិងបូកសរុបសំណើសុំដោះស្រាយបញ្ហាប្រឈមទាំងនោះ និងបញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែរបស់ អ.គ.ហ. ជាមួយ ក.ហ.ស. នៃក្រសួង ស្ថាប័ន ដើម្បីពិភាក្សានិងដោះស្រាយ ដោយមានការចូលរួមពីអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បញ្ហាប្រឈមទាំងឡាយ ដែលត្រូវបានសម្របសម្រួលនិងដោះស្រាយដោយ អ.គ.ហ. ត្រូវរាយការណ៍ជូនប្រធាន គ.ហ.ស.។

បញ្ហាប្រឈមទាំងឡាយដែលត្រូវបានលើកឡើងដោយ ក.ហ.ស.នៃក្រសួង ស្ថាប័ន និងពុំអាចដោះស្រាយបានក្នុងកម្រិត អ.គ.ហ. ត្រូវលើកយកមកដោះស្រាយ នៅក្នុងយន្តការសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងចំណុច ក. ខាងលើ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន ត្រូវអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព ភាពជាម្ចាស់ និងស្មារតីទទួលខុសត្រូវខ្ពស់។

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥*

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ**
**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**...ត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ